# មេរៀនទី ១២៧: ព្រះយេស៊ូវយាងត្រឡប់ទៅស្ថានសួគ៌វិញ

## ម៉ាថាយ ២៨:១៦-២០, កិច្ចការ ១:១-១១

**គោលបំណង៖** ព្រះបានជួយយើងប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖** ម៉ាថាយ ២៨:១៩ *"ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវជួយយើងឲ្យរីកចម្រើន ហើយទ្រង់ប្រទានពរឱ្យយើងនូវការចូលរួមពេញលេញក្នុងព័ន្ធកិច្ច និងបេសកកម្មរបស់ទ្រង់នៅលើផែនដី។ សូមអានបេសកកម្មដ៏អស្ចារ្យពី **ម៉ាថាយ ២៨:១៦-២០** ឡើងវិញ។ ខគម្ពីរនេះនិយាយថាពួកសិស្សមានការសង្ស័យ។ តើការសង្ស័យអ្វីខ្លះដែលអ្នកកំពុងប្រឈមមុខជាមួយ?ព្រះយេស៊ូវបានចេញការអញ្ជើញ និងជំរុញយ៉ាងខ្លាំងខ្លា។ ព្រះកាយព្រះយេស៊ូវផ្ទាល់បានត្រាស់ហៅអ្នក ដើម្បីអនុវត្តន៍ផែនការរបស់ទ្រង់! តើព្រះបន្ទូលរបស់ព្រះអង្គធ្វើឲ្យអ្នកមានអារម្មណ៍ដូចម្តេច? សូមចំណាយពេលរបស់អ្នកដើម្បីពិភាក្សាពីការសង្ស័យរបស់អ្នកជាមួយព្រះអង្គ ហើយទូលសុំព្រះជួយឲ្យអ្នកមានទំនុកចិត្តនិងពង្រឹងចេត-នា របស់អ្នកដើម្បីចូលរួមជាមួយនឹងព័ន្ធកិច្ចរបស់ព្រះអង្គ។

**ចំរៀង៖** ១. នៅស្ថានសួគ៌មានក្មេងៗ ២. ខ្ញុំដឹងថា ៣. ព្រះគ្រីស្ទទ្រង់រស់ឡើងវិញ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ឈោងចាប់បាល់»

**សម្ភារៈដែលត្រូវការ៖** ខ្សែ កូនបាល់តូចៗ ឬក្រូចឆ្មារក៏បាន



១. ចែកកុមារជា ៤ក្រុម។

២. ប្រើខ្សែធ្វើជារង្វង់ធំមួយ ហើយដាក់បាល់នៅកណ្តាលរង្វង់នោះ (ឬក៏ផ្លែឈើ ឬអាចជាអ្វីក៏បាន ដែលកុមារអាចចាប់បាន)

៣. ឲ្យកុមារឈរជាក្រុមជុំវិញរង្វង់នោះ។

៤. នៅពេលដែលគ្រូរាប់ ១ ២ ៣ ក្រុមនីមួយៗត្រូវជ្រើសរើសមេក្រុមម្នាក់ឲ្យឈោងចាប់បាល់នោះ ដោយសមាជិកក្រុមផ្សេងទៀតជួយកាន់ដៃមេក្រុមនោះ ដើម្បីឲ្យគាត់អាចចាប់បាល់នោះបាន។ ពួកគេមានពេល២នាទីក្នុងការលេងល្បែងនេះ។

៥. ប្រសិនបើមេក្រុមជាន់លើខ្សែ ឬក៏រំលងខ្សែ នោះក្រុមរបស់ពួកគេនឹងចាញ់ល្បែងនេះ។

៦. ក្រុមណាដែលអាចចាប់បាល់បានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាយើងបានជួយគ្នាក្នុងការលេងល្បែងនេះដែរ យើងត្រូវ

ជួយអ្នកដទៃឲ្យជឿលើព្រះយេស៊ូវដោយការចែកចាយដំណឹងល្អរបស់ព្រះអង្គ។

## ៤. ការណែនាំមេរៀន

តើអ្វីជាដំណឹងល្អបំផុតដែលអ្នកធ្លាប់បានឮក្នុងជីវិតរបស់អ្នក? ពេលឮដំណឹងល្អ តើអ្នកចង់ប្រាប់អ្នកណាមុនគេ? តើអ្នកមិនចង់ប្រាប់អ្នកជុំវិញខ្លួនទេឬ? ក្នុងនាមជាគ្រិស្តបរិស័ទដំណឹងល្អបំផុតដែលយើងមានគឺថា ព្រះយេស៊ូវមានអំណាចខ្លាំងណាស់ដែលទ្រង់អាចមើលថែយើងបានល្អ ព្រមទាំងនាំយើងទៅស្ថានសួគ៌ផងដែរ។ តើអ្នកគិតថានេះជាដំណឹងល្អឬទេ? ថ្ងៃនេះ ចូរយើងរៀនពីរបៀបដែលព្រះយេស៊ូវជួយយើងឱ្យប្រាប់ដំណឹងដ៏អស្ចារ្យនេះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ប៉ុន្តែទ្រង់មានព្រះជន្មរស់ឡើងវិញ បន្ទាប់ពីសុគតបានបីថ្ងៃ នេះគឺដោយសារតែព្រះអង្គមានអំណាច! ទ្រង់ពិតជាអស្ចារ្យណាស់ ព្រះអង្គបានយកឈ្នះលើសេចក្ដីស្លាប់! ហើយនេះគឺជាដំណឹងល្អ ពីព្រោះនេះមានន័យថា អ្នករាល់គ្នាដែលជឿលើព្រះយេស៊ូវនឹងមានព្រះដ៏មានអំណាចដើម្បីជួយពួកគេក្នុងជីវិត។ ម្យ៉ាងទៀតនេះមានន័យថា អ្នកជឿទាំងអស់ក៏អាចយកឈ្នះលើសេចក្ដីស្លាប់ ហើយរស់នៅជារៀងរហូតជាមួយព្រះយេស៊ូវនៅឯនគរស្ថានសួគ៌!

បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ទ្រង់បានចំណាយពេល៤០ថ្ងៃនៅលើផែនដី ដើម្បីបង្រៀនអំពីនគរនៃព្រះហើយបង្ហាញមនុស្សថា ទ្រង់ពិតជាមានព្រះជន្មរស់ឡើងវិញមែន។ ព្រះយេស៊ូវបានលើកទឹកចិត្តសិស្សទាំងអស់ឲ្យទៅប្រាប់ដំណឹងល្អនេះ ដល់មនុស្សគ្រប់គ្នាពីគ្រប់ទាំងសាសន៍រហូតដល់ចុងផែនដី។ រួចហើយទ្រង់បានឡើងទៅស្ថានសួគ៌ ខណៈមនុស្សកំពុងមើលព្រះអង្គរហូតដល់ពពកបាំងមើលព្រះអង្គលែងឃើញ។

ព្រះចង់ឲ្យមនុស្សគ្រប់គ្នាក្នុងលោកនេះស្គាល់ព្រះយេស៊ូវ។ ទ្រង់ចង់ឱ្យមនុស្សគ្រប់គ្នាបានសង្គ្រោះ។ ព្រះបានសង្គ្រោះយើង មិនមែនដោយសារតែអំពើល្អដែលយើងធ្វើនោះទេ ប៉ុន្តែដោយសារសេចក្ដីមេត្តាករុណារបស់ទ្រង់។ ព្រះយេស៊ូវបានសង្គ្រោះយើងដោយសារទ្រង់ស្រឡាញ់យើង។ ហើយព្រះយេស៊ូវចង់ឲ្យយើងចែករំលែកសេចក្ដីស្រឡាញ់របស់ទ្រង់ដល់អ្នករាល់គ្នា។

ពេលខ្លះយើងមិនប្រាកដថាត្រូវចែកចាយដំណឹងល្អនេះដល់អ្នកឯទៀតយ៉ាងណាទេ។ យើងមានអារម្មណ៍ខ្មាស់-អៀន ឬមិនដឹងថាត្រូវនិយាយអ្វី។ យើងគួរតែអធិស្ឋានឲ្យព្រះជួយយើង ដើម្បីឲ្យយើងអាចប្រាប់អ្នកដទៃអំពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះមនុស្សគ្រប់រូប។ ព្រះអង្គតែងតែត្រៀមខ្លួនជួយយើងជានិច្ច។ ព្រះមិនសុំឲ្យយើងធ្វើអ្វីដែលទ្រង់មិនជួយយើងធ្វើនោះទេ។ ពេលខ្លះព្រះប្រើមនុស្សផ្សេងទៀតឲ្យជួយយើង ក្នុងការប្រាប់អ្នកឯទៀតអំពីព្រះយេស៊ូវ។ មិត្តភក្តិគ្រីស្ទបរិស័ទរបស់យើងអាចលើកទឹកចិត្តយើង ទៅជាមួយយើងដើម្បីប្រាប់មនុស្ស ឬបន្ថែមទីបន្ទាល់របស់ពួកគេពីលើទីបន្ទាល់របស់យើង ដើម្បីបង្ហាញដល់មនុស្សផ្សេងទៀត។

វិធីមួយទៀតដែលព្រះជួយយើងប្រាប់អ្នកដទៃគឺដោយការផ្លាស់ប្ដូរជីវិតរបស់យើង។ ដោយសារតែព្រះយេស៊ូវបានផ្លាស់ប្ដូរជីវិតរបស់អ្នកនោះអ្នកផ្សេងទៀតនឹងឃើញពីរបៀប ដែលអ្នកកំពុងរស់នៅក្នុងជីវិតរបស់អ្នកខុសគ្នាពីជីវិតរបស់ពួកគេ។ ហើយនេះគឺជារឿងដ៏អស្ចារ្យមួយដើម្បីប្រាប់ និងបង្ហាញហើយបញ្ជាក់ថាព្រះរបស់យើងអស្ចារ្យ

ប៉ុណ្ណា! ព្រះគម្ពីរក៏សន្យាថានឹងជួយយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ **កិច្ចការ ១:៨** ចែងថា «ប៉ុន្តែកាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនិងធ្វើជាទីបន្ទាល់ពីខ្ញុំនៅក្រុងយេរូសាឡិមព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង»។ ពេលយើងគិតថាយើងមិនអាចនឹងចែករំលែកអំពីព្រះទៅកាន់អ្នកដទៃ ប៉ុន្តែយើងមានព្រះវិញ្ញាណបរិសុទ្ធចាំជួយយើង។

យើងអរព្រះគុណព្រះពីព្រោះទ្រង់តែងតែជួយដល់យើងដើម្បីប្រាប់អ្នកដទៃទៀតពីព្រះយេស៊ូវ!

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវបង្ហាញយ៉ាងណាថាទ្រង់មានអំណាច? *ទ្រង់បានឈ្នះសេចក្តីស្លាប់ហើយរស់ឡើងវិញ*

២. តើដំណឹងល្អនេះមានន័យសម្រាប់យើងយ៉ាងណា? *យើងមានវត្តមានព្រះដ៏មានអំណាចគង់នៅជាមួយយើង ហើយយើងក៏អាចយកឈ្នះសេចក្តីស្លាប់ ហើយរស់នៅស្ថានសួគ៌ជាមួយនឹងព្រះជារៀងរហូត*

៣. តើព្រះយេស៊ូវចង់ឲ្យយើងធ្វើអ្វីអំពីដំណឹងល្អនេះ?*ទ្រង់ចង់ឱ្យយើងចែករំលែកដំណឹងល្អនេះដល់អ្នកដទៃ*

៤. តើព្រះយេស៊ូវសន្យានឹងធ្វើអ្វី ពេលយើងព្យាយាមផ្សព្វផ្សាយដំណឹងល្អនេះ? *ទ្រង់សន្យាថានឹងជួយយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ*

## ៧. ល្បែងកំសាន្ត «ធ្វើកាយវិការតាមលេខ»




១. ឲ្យកុមារចាប់ដៃគូពីរៗនាក់ ហើយឈរជាពីរជួរ។

២. នៅពេលដែលគ្រូហៅលេខណាមួយកុមារត្រូវធ្វើកាយវិការដែលតំណាងឲ្យលេខនោះ។ នៅពេលដែលគ្រូនិយាយលេខ១ កុមារត្រូវធ្វើកាយវិការដូចជាទះដៃគ្នា នៅពេលដែលគ្រូនិយាយលេខ ២ កុមារត្រូវអង្គុយចុះ នៅពេលដែលគ្រូនិយាយលេខ ៣ កុមារត្រូវលោតឡើង នៅពេលដែលគ្រូនិយាយលេខ ៤ កុមារត្រូវបង្វិលខ្លួនមួយជុំ។

៣. នៅពេលដែលគ្រូនិយាយលេខណាមួយ កុមារត្រូវធ្វើកាយវិការខុសៗគ្នាតាមលេខដែលគ្រូហៅនោះ។

៤. ប្រសិនបើកុមារមិនអាចធ្វើកាយវិការតាមគ្រូនិយាយបាន នោះគេនិងចាញ់ល្បែងនេះ។

៥. បន្តលេងល្បែងនេះ រហូតដល់នៅសល់កុមារតែមួយគូ ហើយពួកគេជាអ្នកឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ព្រះយេស៊ូវបានធ្វើនូវកិច្ចការជាច្រើនដើម្បីនាំយកដំណឹងល្អមកកាន់លោកីយ៍នេះ។ ក៏ដូចគ្នានេះដែរ យើងគួរតែចែកចាយដំណឹងល្អអំពីព្រះយេស៊ូវទៅកាន់មនុស្សគ្រប់គ្នានៅក្នុងពិភពលោកនេះ។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ២៨:១៩

**៩. ហត្ថកម្ម** ផាត់ពណ៌ «តោះយើងនិយាយអំពីព្រះយេស៊ូវ! »



**សម្ភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសផាត់ពណ៌ កូល័រផាត់ពណ៌

១. ឱ្យកុមារផាត់ពណ៌ឈើឆ្កាង និងផែនដី។

២. សរសេរខគម្ពីរចងចាំ ហើយអានវាឱ្យខ្លាំងជាមួយគ្នា។

៣. ឱ្យកុមារគិតអំពីនរណាម្នាក់ដែលពួកគេអាចប្រាប់អំពីព្រះយេស៊ូវបាន ហើយអធិស្ឋានឱ្យពួកគេ មុនពេលពួកគេទៅចែករំលែកដំណឹងល្អ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# តោះយើងនិយាយអំពីព្រះយេស៊ូវ!



សូមសរសេរខគម្ពីរចងចាំ: ____________________________

______________________________________________

______________________________________________

______________________________________________